រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ
# មហាសន្និបាតភាគហ៊ុនិកលើកទី៦

**ក/.កាលបរិច្ឆេទ** ៖ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ចាប់ពីម៉ោង៨:០០ព្រឹក

**ខ/.ទីកន្លែង** ៖ សាលប្រជុំរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)

**គ/.សមាសភាពចូលរួម៖**

- គណៈអធិបតី ៖
  ១. ឯកឧត្តម សឹម ណាប៉ា ប្រធានក្រុមប្រឹក្សាភិបាល
  ២. ឯកឧត្តម ស៊ឹម ស៊ីថា អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
  ៣. ឯកឧត្តម ម៉ី វ៉ាន់ សមាជិកក្រុមប្រឹក្សាភិបាល - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  ៤. លោកឧកញ៉ា ចាង យុនហ្វេង សមាជិកក្រុមប្រឹក្សាភិបាល - អភិបាលមិនប្រតិបត្តិ តំណាងភាគហ៊ុនិកឯកជន
  ៥. លោក អោម សេងបូ៉ា សមាជិកក្រុមប្រឹក្សាភិបាល - អភិបាលឯករាជ្យ
- ភ្ញៀវកិត្តិយស ៖
  ១. ឯកឧត្តម ជូ វណ្ណៈ តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  ២. លោក ថា វុទ្ធី តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម
  ៣. ឯកឧត្តម សៀង ជីវិទ្ធ តំណាងគណៈកម្មការមូលបត្រកម្ពុជា
  ៤. លោក ល្មុន សូឡី តំណាងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
  ៥. លោក វណ្ណ សំណាង អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (តំណាងមន្ត្រីត្រួតពិនិត្យរដ្ឋ)
  ៦. លោកស្រី សេង គាតារា ប្រធានសវនកម្មផ្ទៃក្នុង រ.ទ.ស.ភ
  ៧. លោក អាន សុជា តំណាងក្រុមហ៊ុនសវនកម្មឯករាជ្យ ប៊ី ឌី អូ (ខេមបូឌា)
  ៨. លោកស្រី ហ៊ី ផានិន តំណាងកំពង់ផែស្វយ័តភ្នំពេញ
  ៩. លោក សម សុភាព តំណាងកំពង់ផែស្វយ័តក្រុងព្រះសីហនុ
  ១០. លោក ស៊ីយ៉ា ម៉ាលីដា តំណាងធនាគារអេស៊ីលីដា ភីអិលស៊ី
  ១១. លោក ព្រំ វិសុទ្ធ តំណាងអេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី
  ១២. លោក លីហ៊ូ សេងហ៊ុន តំណាងក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី
  ១៣. លោក ស៊ឹម តារា តំណាងក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី ភីអិលស៊ី
  ១៤. លោក Lim Long Seng តំណាងក្រុមហ៊ុន អ អេច ប៊ី ឥណ្ឌូឆាយណា ស៊ីឃ្យូរីធី
  ១៥. លោកស្រី ឆាយ ស៊ីវហួយ តំណាងក្រុមហ៊ុន កាណា ស៊ីឃ្យូរីធី អិលធីឌី
  ១៦. លោកស្រី ស៊ីប ឡៃហេង តំណាងក្រុមហ៊ុន អេស ប៊ី អាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី
  ១៧. លោក Zhang Ling Feng តំណាងក្រុមហ៊ុន ហ្គោលដេន ហ្វ័រឈូន ស៊ីឃ្យូរីធី
  ១៨. លោក ស៊ីណា ណូប៉ា តំណាងក្រុមហ៊ុន ខេប ស៊ីឃ្យូរីធី លីមីធីត

- លេខាកត់ត្រា ៖ ១. លោកបណ្ឌិត ជា វិសុទ្ធ អគ្គនាយករងទទួលបន្ទុកជាលេខាសហគ្រាស
២. លោក ហួត សុខហេង នាយលេខាធិការដ្ឋាន។
- អ្នកចូលរួម ៖ ចំនួនភាគហ៊ុនិកដែលបានចុះឈ្មោះនៅភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្ររបស់ រ.ទ.ស.ភ (ធនាគារអេស៊ីលីដា ភីអិលស៊ី) ដើម្បីត្រៀមចូលរួមមហាសន្និបាតមានចំនួន១៤៩នាក់ គិតជាភាគហ៊ុនមានចំនួន៧៦.១៣៤.០៣២ហ៊ុន ស្មើនឹង៨៧,៥៤%នៃភាគហ៊ុនធម្មតាសរុប។ ភាគហ៊ុនិកដែលបានចុះវត្តមាននិងបានចូលរួមមហាសន្និបាតជាក់ស្តែងមានចំនួន១០០នាក់ គិតជាភាគហ៊ុនមានចំនួន៧៥.៩៧៣.៣៦១ហ៊ុន (ស្មើនឹង៩៩.៧៩%នៃចំនួនភាគហ៊ុនដែលបានចុះឈ្មោះចូលរួម) ក្នុងនោះមានឯកឧត្តម ជូ វណ្ណៈ អគ្គនាយករងនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ជាអាណត្តិគាហកៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដោយឡែកភាគហ៊ុនិកដែលមិនបានចុះឈ្មោះ តែបានចូលរួមមហាសន្និបាត មានចំនួន៩៩នាក់។ ជាសរុប មានចំនួន១៩៩នាក់។

### ឃ/.ដំណើរការនៃមហាសន្និបាត

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម សឹម ណារ៉ា** ប្រធានក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ និងជាប្រធានគណៈអធិបតី នៃអង្គមហាសន្និបាត បានថ្លែងសន្ទរកថាស្វាគមន៍បើកដំណើរការមហាសន្និបាតភាគហ៊ុនិកលើកទី៦ ក្នុងគោលបំណងគឺដើម្បីរាយការណ៍ជូនភាគហ៊ុនិកទាំងអស់បានជ្រាបអំពីលទ្ធផលអាជីវកម្មឆ្នាំ២០១៧ និងទិសដៅអាជីវកម្មឆ្នាំ២០១៨របស់ រ.ទ.ស.ភ ។ ក្នុងសន្ទរកថានោះ ឯកឧត្តមបានជម្រាបគ្រួសៗជូនអង្គមហាសន្និបាត អំពីលទ្ធផលអាជីវកម្មដែល រ.ទ.ស.ភ ខិតខំសម្រេចបានក្នុងឆ្នាំ២០១៧កន្លងទៅ ដោយផលិតទឹកស្អាតសរុបបាន ១៩៤.០៣៧.៨៣៣ម$^{៣}$, ដាក់បណ្តាញចែកចាយទឹកថ្មីបានប្រវែង ១៩៥.៣៧៧ម៉ែត្រ និងតបណ្តាញចូលផ្ទះថ្មីបានចំនួន ២២.៤៥៣បណ្តាញ (ក្នុងនោះបណ្តាញអតិថិជនចំណូលទាបមានចំនួន៥៤២គ្រួសារ)។ ក្រៅពីនេះ ចំណូលសរុបមានចំនួន ២៣២.៨៩៣លានរៀល និងចំណេញក្រោយបង់ពន្ធមានចំនួន៣៣.០៦៧លានរៀល ដោយចំណេញជាមូលដ្ឋានក្នុងមួយភាគហ៊ុន (Basic Earnings per Share) គឺ ៣៨០,២១រៀល។

ឯកឧត្តមប្រធានគណៈអធិបតី ក៏បានមានប្រសាសន៍បន្ថែមទៀតថា ៖ ក្រោយពីការបែងចែកប្រាក់ចំណេញតាមលក្ខន្តិកៈ រ.ទ.ស.ភ ទឹកប្រាក់ដែលនៅសល់មានចំនួន ២៩.៧៦១.០៤៣.៤០០រៀល។ ក្នុងសម័យប្រជុំលើកទី៦ កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ ក្រុមប្រឹក្សាភិបាលបានឯកភាពជាឯកច្ឆ័ន្ទ រក្សាទុកប្រាក់ចំណេញចំនួន១៦.៣៦៧.១៧៦.៤៥២រៀល សម្រាប់ការវិនិយោគទៅអនាគត និងទឹកប្រាក់នៅសល់ចំនួន ១៣.៣៩៣.៨៦៦.៩៤៨រៀល សម្រាប់បែងចែកភាគលាភជូនភាគហ៊ុនិក។

បើធៀបទៅនឹងឆ្នាំ២០១៦ ប្រាក់ចំណេញបានថយចុះពិតមែន ក៏ប៉ុន្តែដោយចង់រក្សាទិន្នផលភាគលាភ (Dividend Yield) ៤% ដែលប្រហាក់ប្រហែលនឹងអត្រាការប្រាក់អប្បបរមានៃប្រាក់បញ្ញើនៅធនាគារ ជាការលើកទឹកចិត្តដល់ម្ចាស់ភាគហ៊ុន ក្រុមប្រឹក្សាភិបាលបានសម្រេចបែងចែកភាគលាភក្នុងមួយភាគហ៊ុន (Dividend per share) ចំនួន១៥៤រៀល ហើយភាគលាភនេះបានចាប់ផ្តើមទូទាត់ជូនភាគហ៊ុនិក ចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៨។ ជាមួយគ្នានេះដែរ ក្រុមប្រឹក្សាភិបាលបានអនុម័តស្នើសុំមិនទូទាត់ភាគលាភឆ្នាំ២០១៧ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទេ ដើម្បីរក្សាទុកថវិកានេះសម្រាប់ការងារវិនិយោគជាបន្តទៀត។

## ១/.បទបង្ហាញស្តីពីលទ្ធផលអាជីវកម្មឆ្នាំ២០១៧ និងទិសដៅអាជីវកម្មឆ្នាំ២០១៨

បន្ទាប់ពីសន្ទរកថាស្វាគមន៍របស់ឯកឧត្តមប្រធានគណៈអធិបតី លោក រស់ គឹមលាង អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ចនិងផ្សារមូលបត្រ បានធ្វើបាយការណ៍លម្អិតជូនអង្គមហាសន្និបាតជ្រាបអំពីលទ្ធផលអាជីវកម្មឆ្នាំ២០១៧និងទិសដៅអាជីវកម្មឆ្នាំ២០១៨ តាមរយៈការបញ្ចាំងស្លាយជាភាសាខ្មែរនិងភាសាអង់គ្លេស ដោយមានខ្លឹមសារសំខាន់ៗដូចមានក្នុងឯកសារដាក់ជូនមហាសន្និបាត។ លោកក៏បានធ្វើការកត់សម្គាល់ផងដែរថា ៖

- អនុបាតនៃការបែងចែកភាគលាភ (Dividend Payout Ratio) ឆ្នាំ២០១៧ គឺ ៤០,៥០% នៃប្រាក់ចំណេញ ដោយមួយភាគហ៊ុនទទួលបាន១៥៤រៀល ដែលប្រហាក់ប្រហែលទៅនឹងឆ្នាំ២០១៦ (១៥៩,៩៩ រៀល/ភាគហ៊ុន)។
- បើធៀបនឹងឆ្នាំ២០១៦ សមាសភាពក្រុមប្រឹក្សាភិបាលមានការផ្លាស់ប្តូរសមាជិកចំនួន២រូប ក្នុងនោះ លោក ឡុង ណារ៉ូ អគ្គនាយករងទទួលបន្ទុកសាខាសេវាកម្មទឹកស្អាតនិងអនាម័យ នៃ រ.ទ.ស.ភ ត្រូវបានបោះឆ្នោតជ្រើសរើសជាតំណាងនិយោជិត រ.ទ.ស.ភ ជាសមាជិកក្រុមប្រឹក្សាភិបាល ជំនួសលោកស្រី ងិន ចន្ទ្រា និងឯកឧត្តម នួន ផារ័ត្ន អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល ជំនួសឯកឧត្តម ឃួង ស្រេង ដែលត្រូវបានរាជរដ្ឋាភិបាលតែងតាំងជាអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ។
- នៅក្នុងអង្គការលេខរបស់ រ.ទ.ស.ភ មានការបង្កើតបន្ថែមនូវអង្គភាពថ្មីមួយ ក្រោមការគ្រប់គ្រងរបស់ឯកឧត្តមអគ្គនាយកផ្ទាល់ គឺអង្គភាពនីតិកម្មនិងអធិការកិច្ច ដែលបំបែកចេញពីអង្គភាពសវនកម្មផ្ទៃក្នុង។
- ផ្ទៃសេវាទឹកស្អាតបច្ចុប្បន្ន គ្របដណ្តប់ប្រមាណ៨៦% នៃចំនួនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ (បើគិតជាចំនួនប្រជាជន)។ ជាទិសដៅ ត្រឹមឆ្នាំ២០២៥ រ.ទ.ស.ភ ខិតខំផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ឲ្យបាន១០០% ស្របទៅតាមគោលនយោបាយទឹកស្អាតរបស់រាជរដ្ឋាភិបាលកម្ពុជា។
- បណ្តាញចែកចាយទឹកស្អាតរបស់ រ.ទ.ស.ភ មានប្រវែងសរុប ២.៨៤៥គ.ម។ បច្ចុប្បន្ន រ.ទ.ស.ភ មានសមត្ថភាពដាក់បំពង់ចែកចាយទឹកដោយខ្លួនឯង រហូតដល់អង្កត់ផ្ចិត២ម៉ែត្រ ដោយមិនជួលក្រុមហ៊ុនឯកជន ដែលជាហេតុជួយកាត់បន្ថយថ្លៃដើមនៃបំពង់ដែលបានកត់ត្រាក្នុងបញ្ជីអចលនទ្រព្យ។ លើសពីនេះ សាខាសេវាកម្មទឹកស្អាតនិងអនាម័យ មិនត្រឹមតែដាក់បំពង់នៅរាជធានីភ្នំពេញទេ ប៉ុន្តែថែមទាំងទទួលម៉ៅការដាក់បំពង់ឲ្យរដ្ឋាករទឹកនៅតាមបណ្តាខេត្តទៀតផង ដូចជាខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពត ហើយថ្មីៗនេះ នៅខេត្តសៀមរាប។
- ប្រាក់ចំណេញពិតមានចំនួនប្រមាណ ៣៣ពាន់លានរៀល ថយចុះជាង ១៦ពាន់លានរៀល បើធៀបនឹងឆ្នាំ២០១៦ ដែលមានរហូតដល់៤៩ពាន់លានរៀល។ កត្តាចំបងនៃការថយចុះនេះ បណ្តាលមកពីការខាតបង់ហិរញ្ញវត្ថុសុទ្ធប្រមាណ ២៦ពាន់លានរៀល ក្នុងនោះការខាតសុទ្ធពីអត្រាប្តូររូបិយប័ណ្ណអឺរ៉ូធៀបនឹងប្រាក់រៀល ក្រោមកម្ចីផ្ទាល់ពី AfD មានរហូតដល់ជាង ២៣ពាន់លានរៀល។ ដោយឡែក ប្រាក់ចំណេញសុទ្ធពីប្រតិបត្តិការក្នុងឆ្នាំ២០១៧ គឺ ៧៩ពាន់លានរៀល មានការកើនឡើង បើធៀបនឹងឆ្នាំ២០១៦ ដែលមានតែ៥៧ពាន់លានរៀល។
- បណ្តាសន្ទស្សន៍សំខាន់ៗដែលសម្រេចបានក្នុងឆ្នាំ២០១៧ គឺ ៖

| | | |
|---|---|---|
| ១. | អនុបាតចរន្ត | ២,៥៦ ដង |
| ២. | អត្រាអនុបាតចរន្តលឿន | ១,៩៧ ដង |
| ៣. | ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម | ២,៤៩% |
| ៤. | ផលចំណេញក្នុងមួយឯកតាមូលធន | ៣,៩៩% |
| ៥. | អត្រាទឹកបាត់បង់ | ៨,៣០% |
| ៦. | អត្រាទារប្រាក់ | ៩៩,៩០% |

- ទិសដៅសំខាន់ៗនៃអាជីវកម្មក្នុងឆ្នាំ២០១៨ គឺ ៖

| | | |
|---|---|---|
| ១. | ដាក់បណ្តាញចែកចាយទឹកស្អាតបន្ថែម | ២៥០ គ.ម |
| ២. | តបណ្តាញចូលផ្ទះថ្មីចំនួន | ២២.០០០ បណ្តាញ |
| ៣. | ចំនួនអតិថិជនចុងគ្រានាដំណាច់ឆ្នាំ២០១៨ | ៣៦២.៣០០ បណ្តាញ |

| | | |
|---|---|---|
| ៤. | បរិមាណទឹកលក់ | ១៩១.៣៦០.៣៦៤ ម៣ |
| ៥. | បរិមាណទឹកផលិត | ២០៩.១៣៧.០០០ ម៣ |
| ៦. | អត្រាធ្វើវិក្កយបត្រ | ៩១,៥០% |
| ៧. | អត្រាទារប្រាក់ | ៩៩,៩០% |
| ៨. | ថ្លៃទឹកលក់ជាមធ្យម/ម៣ | ៩៩៥ រៀល |
| ៩. | ចំណូលសរុប | ២៤៣.៥០៩.២៦៤.០០០ រៀល |
| ១០. | ចំណាយសរុប | ១៨៥.៨២៣.៤៩៨.០០០ រៀល |
| ១១. | ចំណេញពិត | ៤៦.១៤៨.៦១៣.០០០ រៀល។ |

## ២/. សំណួរ-ចម្លើយ

ភាគហ៊ុនិកដែលបានចូលរួមមហាសន្និបាត បានចោទសួរ លើកសំណូមពរ និងផ្តល់អនុសាសន៍ដូចខាងក្រោម ៖

១. *តើ រ.ទ.ស.ភ មានការគិតគូរទៅលើ (ក) ការតម្លើងថ្លៃទឹក ឬបង្កើនការវិនិយោគបន្ថែមទៀតឬទេ ខណៈដែលថ្លៃទឹកពុំធ្លាប់បានតម្លើងទាល់តែសោះ ក្នុងរយៈពេល១៥ឆ្នាំកន្លងមក? (ខ) ការប្រើប្រាស់ឲ្យអស់ពីប្រសិទ្ធភាពក្នុងការវិនិយោគសាច់ប្រាក់ដែលនៅសល់ ដើម្បីទទួលបានផលចំណេញអតិបរមា (Hedge Funds) ដែរឬទេ?*

ឆ្លើយតបនឹងចំណុច (ក) នៃសំណួរនេះ ឯកឧត្តមប្រធានគណៈអធិបតី បានមានប្រសាសន៍បកស្រាយថា រ.ទ.ស.ភ គឺជាអង្គភាពអាជីវកម្មដែលស្វែងរកប្រាក់ចំណេញផង និងគិតគូរអំពីសង្គមផង ដូច្នេះ ទើបក្រុមប្រឹក្សាភិបាលបានគិតគូររួចហើយថា តើក្នុងស្ថានភាពបែបណា ទើបយើងតម្លើងថ្លៃទឹក? ដោយបច្ចុប្បន្ន ស្ថានភាពចំណូលរបស់ប្រជាពលរដ្ឋ នៅមានកម្រិតទាបនៅឡើយ នោះការតម្លើងថ្លៃទឹកគឺមានការលំបាក។ តែទោះជាយ៉ាងណា ទៅថ្ងៃអនាគត យើងនឹងស្នើសុំរាជរដ្ឋាភិបាល ដើម្បីពិនិត្យមើលឡើងវិញនូវថ្លៃទឹករបស់ រ.ទ.ស.ភ ដោយផ្តោតជាសំខាន់ទៅលើ ២ចំណុចគឺ ៖

ទី១- របៀបនៃការគណនាថ្លៃទឹក ពីព្រោះសព្វថ្ងៃនេះ មានអ្នកប្រើប្រាស់ទឹកតិច និងច្រើនលើសកម្រិត សម្រាប់ជីវភាពធម្មតា និងការប្រើប្រាស់នៅក្នុងឧស្សាហកម្ម។ ដោយហេតុនេះ ទើបតម្រូវឲ្យមានការវិភាគល្អិតល្អន់ក្នុងការរៀបចំសេណារីយ៉ូ ដោយផ្អែកលើស្ថានភាពដែលមានស្រាប់ទាំងអស់នេះ។

ទី២- ការពង្រីកវិសាលភាពក្នុងការផ្គត់ផ្គង់ទឹក ក្នុងគោលបំណងប៉ះប៉ូវខ្លះដល់ការដែលមិនទាន់អាចតម្លើងថ្លៃទឹកបាន។ ដើម្បីពង្រីកវិសាលភាពនេះ ទាមទារឲ្យមានការវិនិយោគបន្ថែមទៅលើបណ្តាញទឹក ក៏ដូចជាការសាងសង់រោងចក្រថ្មីៗ។ បច្ចុប្បន្ន យើងកំពុងពង្រីកសមត្ថភាពរោងចក្រផលិតទឹកស្អាតចំការមន ហើយនាពេលខាងមុខ រ.ទ.ស.ភ មានគម្រោងសាងសង់រោងចក្រផលិតទឹកស្អាតធំមួយទៀត គឺរោងចក្របាក់ខែង ដែលនឹងធ្វើឲ្យសមត្ថភាពផ្គត់ផ្គង់នៅឆ្នាំ២០២៥ ស្មើនឹង២ដង នៃសមត្ថភាពផលិតបច្ចុប្បន្ន (៥៧០.០០០ម៣/ថ្ងៃ)។ ដើម្បីអាចអនុវត្តគម្រោងធំៗបែបនេះទៅបាន តម្រូវឲ្យមានការផ្តល់ហិរញ្ញប្បទាន ហើយអ្នកផ្តល់ហិរញ្ញប្បទាននឹងពិចារណាទៅលើលទ្ធភាពសងបំណុលរបស់អង្គភាព ដូច្នេះនាំឲ្យមានការពិភាក្សាគ្នាអំពីប្រាក់ហិរញ្ញប្បទាន និងអត្រាការប្រាក់ ជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាក្រសួងអាណាព្យាបាល។ ជាចុងក្រោយ វានឹងពាក់ព័ន្ធនឹងថ្លៃទឹក។

ឆ្លើយតបនឹងចំណុច (ខ) នៃសំណួរនេះ ឯកឧត្តម ម៉ី វ៉ាន់ សមាជិកក្រុមប្រឹក្សាភិបាល និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ នៃក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ បានឆ្លើយបំភ្លឺជូនអង្គមហាសន្និបាតជ្រាបថា បច្ចុប្បន្ននេះ រ.ទ.ស.ភ បាននិងកំពុងដើរតួជាសហគ្រាសរដ្ឋ ដែលបានយកចិត្តទុកដាក់ទៅលើ៣ចំណុច ៖ ទី១-រក្សានិរន្តរភាពនៃដំណើរការអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត, ទី២-គិតគូរអំពីតម្លៃទឹក ដោយធ្វើការថ្លឹងថ្លែងទៅលើកត្តាប្រាក់ចំណេញ និងកត្តាសង្គម ជាពិសេសសុខមាលភាពរបស់ប្រជាពលរដ្ឋ និងទី៣-វិនិយោគសាច់ប្រាក់ដែលនៅសល់ តាមរយៈការតម្កល់ប្រាក់

នៅធនាគារដើម្បីយកការប្រាក់។ ទន្ទឹមនឹងនោះ ឯកឧត្តមក៏បានគូសបញ្ជាក់ថា អត្រាការប្រាក់បច្ចុប្បន្ននៅកម្ពុជា មានកម្រិតខ្ពស់ បើធៀបទៅនឹងជម្រើសផ្សេងៗទៀត នៃការគៀងគរប្រាក់ចំណេញនោះ។ ការដាក់ប្រាក់នៅធនាគារដើម្បីយកការប្រាក់ និងការគិតគូរល្អិតល្អន់អំពីអត្រាប្តូរប្រាក់រូបិយប័ណ្ណដែល រ.ទ.ស.ភ កំពុងអនុវត្ត គឺជាជម្រើសប្រសើរបំផុតហើយ។ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ នៃក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ កំពុងតែគិតគូរអំពីការអនុវត្តនូវគោលនយោបាយនៃការវិនិយោគសាច់ប្រាក់ដែលនៅសល់នេះ។ ជាធម្មតា កាលណាយើងប្រថុយនឹងហានិភ័យខ្ពស់ យើងក៏អាចចំណេញប្រាក់បានច្រើន (High risk, high return)។

២. *រ.ទ.ស.ភ គួរតែគិតគូរពីការកំណត់នូវវិធីសាស្ត្រ និងធនធានមនុស្សសម្រាប់ការងារតាមដាន និងវិភាគទៅលើស្ថានភាពអត្រាប្តូររូបិយប័ណ្ណ និងបំណុលរបស់អង្គភាព ក្នុងគោលបំណងធ្វើយ៉ាងណាប្រើប្រាស់សាច់ប្រាក់ប្រកបដោយប្រសិទ្ធភាព។*

ឆ្លើយតបនឹងសំណួរនេះ ឯកឧត្តម ម៉ី វ៉ាន់ បានថ្លែងអំណរគុណ និងសន្យាយកអនុសាសន៍នេះទៅគិតគូរបន្ថែមទៀត។ ឯកឧត្តមបានមានប្រសាសន៍ថា បច្ចុប្បន្ននេះ ថ្នាក់ដឹកនាំ រ.ទ.ស.ភ បាននិងកំពុងគិតគូរអំពីបញ្ហានេះហើយ ដោយក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនីមួយៗ មានការសួរដេញដោលស៊ីជម្រៅ ធ្វើយ៉ាងណាកាត់បន្ថយហានិភ័យឲ្យនៅកម្រិតអប្បបរមា ក្នុងគោលបំណងប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ឲ្យមានប្រយោជន៍ និងជានានិរន្តរភាពនៃដំណើរការរបស់ រ.ទ.ស.ភ ។

ឯកឧត្តមក៏បានថ្លែងបញ្ជាក់បន្ថែមថា ក្នុងករណីមានការប្រជុំក្រុមបច្ចេកទេសលម្អិត យើងអាចនឹងអញ្ជើញគ្រប់តំណាងភាគីពាក់ព័ន្ធនឹងភាគហ៊ុនរបស់ រ.ទ.ស.ភ ដើម្បីចូលរួមពិភាក្សារកដំណោះស្រាយល្អៗ ពីព្រោះបច្ចុប្បន្ននេះ ទីផ្សារហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា នៅពុំទាន់ទូលំទូលាយ ដែលធ្វើឲ្យ រ.ទ.ស.ភ អាចមានជម្រើសច្រើនក្នុងការធ្វើអ្វីមួយទៅតាមបទពិសោធន៍ដែលខ្លួនមាន។

៣. *តើផ្សារមូលបត្រកម្ពុជា (ផ.ម.ក) មានផែនការ ៖ (ក) អភិវឌ្ឍគេហទំព័ររបស់ខ្លួនដែរទេ ដោយសារខ្លឹមសារនៃសេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ផ.ម.ក ត្រង់ចំណុចការអនុវត្តយុទ្ធសាស្ត្រហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ របស់រាជរដ្ឋាភិបាល ក៏ដូចជាបេសកកម្ម និងចក្ខុវិស័យរបស់ ផ.ម.ក ហាក់ពុំទាន់ធ្វើបច្ចុប្បន្នភាពនៅឡើយ? (ខ) ទាក់ទាញវិនិយោគិន ដើម្បីបង្កើនការចុះបញ្ជីក្រុមហ៊ុនថ្មីៗបន្ថែមទៀតឬទេ?*

ឆ្លើយតបនឹងសំណួរនេះ លោក លួន សូឡី តំណាងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានមានប្រសាសន៍បំភ្លឺដូចខាងក្រោម ៖

(ក) តាមការពិត ខ្លឹមសារដែលលើកឡើងអំពីការអនុវត្តយុទ្ធសាស្ត្រហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ គឺគ្រាន់តែជាការសរសេរយោងចំណុចមួយនៅក្នុងយុទ្ធសាស្ត្រនោះ ដើម្បីឈានទៅបង្កើត ផ.ម.ក ប៉ុណ្ណោះ ដូចនេះមិនចាំបាច់ធ្វើបច្ចុប្បន្នភាពទេ។ ចំណែកឯចំណុចបេសកកម្ម និងចក្ខុវិស័យរបស់ ផ.ម.ក ក៏មិនមានអ្វីដែលត្រូវកែប្រែដែរ។

(ខ) ផ្សារមូលបត្រ គឺជាច្រកមួយដើម្បីជួយឲ្យក្រុមហ៊ុនផ្សេងៗ អាចប្រមូលទុនសម្រាប់ពង្រីក-ពង្រឹងអាជីវកម្មរបស់ខ្លួន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤. *តើលោកឧកញ៉ា ចាង យុនហ្វេង ដែលជាអភិបាលមិនប្រតិបត្តិ តំណាងភាគហ៊ុនិកឯកជន បានជ្រាបអំពីចំនួនភាគហ៊ុនសរុបនាបច្ចុប្បន្នរបស់មន្ត្រី-និយោជិត រ.ទ.ស.ភ ឬទេ? ព្រោះកាលពីឆ្នាំ២០១២ មន្ត្រី-និយោជិតសរុបចំនួន៤៥១នាក់ (រួមទាំងអភិបាល១រូប) ត្រូវបានអនុញ្ញាតឲ្យខ្ចីលុយពី រ.ទ.ស.ភ ដើម្បីទិញភាគហ៊ុន ហើយបច្ចុប្បន្ន មន្ត្រី-និយោជិតមួយចំនួនបានចូលនិវត្តន៍ និងមួយចំនួនទៀតក៏បានទទួលមរណភាពផងដែរ។*

ឆ្លើយតបនឹងសំណួរនេះ លោកឧកញ៉ាមានប្រសាសន៍ថា ពុំបានជ្រាបច្បាស់អំពីចំនួននោះទេ តែបានបញ្ជាក់ថា នៅពេល រ.ទ.ស.ភ លក់ភាគហ៊ុនជាលើកដំបូង ទាំងលោកឧកញ៉ាផ្ទាល់ និងក្រុមហ៊ុន ហ្គោលដេន ហ្វ័រឈូន ស៊ីឃ្យូរីធី (Golden Fortune Securities) បានទិញប្រមាណ២,៤លានភាគហ៊ុន ដែលបានកាន់កាប់រហូតមកដល់បច្ចុប្បន្ន។ ក្នុងករណីចង់ដឹងពីទំហំមូលបត្រដែលបានជួញដូរនៅលើទីផ្សារ លោកឧកញ៉ានឹងស្នើសុំ ផ.ម.ក ជួយផ្តល់នូវទិន្នន័យបច្ចុប្បន្នភាព លម្អិត និងបកស្រាយជូនតាមក្រោយ។

*៥. ភ្ជាប់ទៅនឹងសំណួរទី៤ សំណូមពរឲ្យមានការបំភ្លឺ និងដំណោះស្រាយពាក់ព័ន្ធនឹងនីតិវិធីក្នុងការទូទាត់សងជូន រ.ទ.ស.ភ វិញ ពីភាគហ៊ុនិកដែលជាមន្ត្រី-និយោជិត រ.ទ.ស.ភ ។*

ឆ្លើយតបនឹងសំណួរនេះ ឯកឧត្តម ម៉ី វ៉ាន់ ក៏បានបំភ្លឺជូនមហាសន្និបាតជ្រាបថា ការផ្តល់ឥណទានដល់មន្ត្រី-និយោជិតដើម្បីទិញមូលបត្រ គឺជាបុរេលក្ខខណ្ឌមានចែងនៅក្នុងឯកសារប្រកាសលក់ភាគហ៊ុនជាលើកដំបូងរបស់ រ.ទ.ស.ភ ដែលបានបង្ហាញជាសាធារណៈរួចហើយ។ ការផ្តល់ឥណទាននេះ មានគោលបំណងលើកទឹកចិត្តដល់មន្ត្រី-និយោជិត ចំពោះការខិតខំប្រឹងប្រែងនៅក្នុងដំណើរការរបស់ រ.ទ.ស.ភ និងមួយទៀត ជាលក្ខខណ្ឌសម្រាប់គ្រប់សហគ្រាសទាំងអស់ ដែលចង់បោះផ្សាយលក់ភាគហ៊ុន ត្រូវគិតគូរពីសុខភាពខួរក្បាលរបស់និយោជិតខ្លួន។ ដូច្នេះឥណទាននេះមិនទាន់តម្រូវឲ្យមន្ត្រី-និយោជិត រ.ទ.ស.ភ សងមកវិញ ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសងជំនួស រ.ទ.ស.ភ នោះទេ។ ឯកឧត្តមបានបញ្ជាក់ថា គោលបំណងនៃសំណួរនេះ គឺគេចង់ដឹងថាហេតុអ្វីបានជា រ.ទ.ស.ភ មិនរកចំណេញឲ្យបានច្រើន និងចែកភាគលាភដល់ភាគហ៊ុនិកឲ្យបានច្រើន?

បើយើងគិតតែទៅលើការគៀងគរប្រាក់ចំណេញ (Hedge Fund), តែទៅលើការប្រើប្រាស់បំណុលឲ្យមានប្រសិទ្ធភាព និងតែអំពីតម្លៃទឹក មានន័យថាយើងយកចិត្តទុកដាក់តែទៅលើអាជីវកម្មមួយមុខគត់។ បើក្រឡេកមើលអំពីបេសកកម្មវិញ រ.ទ.ស.ភ មានបេសកកម្មចំនួន២ គឺដើម្បីជានានិរន្តរភាពនៃដំណើរការរបស់សហគ្រាសនេះ និងដើម្បីបំពេញចិត្តវិនិយោគិន ពោលគឺយើងមានប្រាក់ចំណេញ(ភាគលាភ)ដែលប្រហាក់ប្រហែលគ្នាទៅនឹងការប្រាក់ដែលបានពីការដាក់ប្រាក់នៅធនាគារ ហើយភាគលាភនោះទៀតសោតក៏អាចមានភាពរឹងមាំ និងគ្មានហានិភ័យផងដែរ។

## ៣/. មតិបញ្ចប់ និងសេចក្តីថ្លែងអំណរគុណ

ផ្អែកលើលទ្ធផលលម្អិតដែលលើកឡើងក្នុងបទបង្ហាញខាងលើ ឯកឧត្តមប្រធានគណៈអភិបតី បានវាយតម្លៃថា៖ រ.ទ.ស.ភ បានទទួលជោគជ័យក្នុងប្រតិបត្តិការរបស់ខ្លួននាឆ្នាំ២០១៧កន្លងទៅ ហើយក្នុងឆ្នាំ២០១៨នេះ រ.ទ.ស.ភ ត្រូវបន្តប្រតិបត្តិការរបស់ខ្លួន ដើម្បីជោគជ័យជាបន្តទៅទៀត។

ជាមួយនឹងទិសដៅដែលបានគ្រោងទុកសម្រាប់ឆ្នាំ២០១៨ យើងក៏មានការលំបាកមួយចំនួន ដោយយើងចាប់ផ្តើមផ្គត់ផ្គង់ទឹកស្អាតទៅសង្កាត់ក្បាលកោះ, សង្កាត់ព្រែកឯង, សង្កាត់ព្រែកថ្មី និងសង្កាត់វាលស្បូវ នៃខណ្ឌច្បារអំពៅ ដែលជាអតីតតំបន់សេវាកម្មផ្គត់ផ្គង់ទឹករបស់ក្រុមហ៊ុន Mekong Portable Water Construction ។ ដោយហេតុថាបំពង់ផ្គង់ផ្គង់ទឹកមានស្រាប់ក្នុងតំបន់នេះ ពុំមានលក្ខណៈស្តង់ដារ និងរៀបរយដូច រ.ទ.ស.ភ ក្រោយពីការបញ្ចូលទឹកពី រ.ទ.ស.ភ ទៅចែកចាយក្នុងតំបន់ទាំងនេះ ឃើញថាមានការលិចធ្លាយជាច្រើនកន្លែង និងជារៀងរាល់ថ្ងៃ។ ជាមួយគ្នានេះដែរ បណ្តាញអតិថិជននៅមិនទាន់រៀបរយតាមស្តង់ដារដូចអ្វីដែល រ.ទ.ស.ភ កំពុងអនុវត្តនោះឡើយ។

ឯកឧត្តមក៏បានថ្លែងបញ្ជាក់បន្ថែមថា៖ តាមការប្រមើលមើល បរិមាណទឹកបាត់បង់អាចនឹងកើនឡើងក្នុងឆ្នាំ២០១៨នេះ។ តែទោះបីជាយ៉ាងណា ក្រុមប្រឹក្សាភិបាល និងមន្ត្រី-និយោជិត រ.ទ.ស.ភ គ្រប់ជាន់ថ្នាក់ នឹងខិតខំដោះស្រាយនូវការលំបាក និងបញ្ហាប្រឈមទាំងអស់នេះ ឲ្យបានជោគជ័យ។

ឆ្លៀតឱកាសនេះដែរ ខ្ញុំក៏សូមថ្លែងសរសើរ ចំពោះគណៈកម្មការរៀបចំ និងដំណើរការមហាសន្និបាតភាគហ៊ុនិកលើកទី៦ ដែលបានខិតខំធ្វើឲ្យមហាសន្និបាតនេះ ប្រព្រឹត្តទៅដោយរលូន។

ជាកិច្ចបញ្ចប់នៃមហាសន្និបាត ឯកឧត្តមប្រធានគណៈអធិបតីនៃអង្គមហាសន្និបាត បានថ្លែងអំណរគុណចំពោះគណៈអធិបតី ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ និងសមាជិកនៃអង្គសន្និបាតទាំងមូល ដែលបានអញ្ជើញចូលរួម និងបានធ្វើឲ្យមហាសន្និបាតភាគហ៊ុនិកលើកទី៦របស់ រ.ទ.ស.ភ ប្រព្រឹត្តទៅដោយជោគជ័យ។

មហាសន្និបាតបានបញ្ចប់នាម៉ោង១០:៤០នាទីព្រឹក នៃថ្ងៃនិងខែឆ្នាំដដែល។

**លេខាធិការសហគ្រាស**

បណ្ឌិត ជា ទិសុទ្ធ

**ប្រធានគណៈអធិបតីនៃអង្គមហាសន្និបាត**
**ប្រធានក្រុមប្រឹក្សាភិបាល**

សឹម_ណារ៉ា

**<u>កន្លែងទទួល</u> :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ឯកឧត្តមប្រធាន និងគ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- មន្ត្រីត្រួតពិនិត្យរដ្ឋអមរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- គណៈកម្មការមូលបត្រកម្ពុជា

  *"ដើម្បីជូនជ្រាប"*
- គ្រប់អង្គភាពចំណុះរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

  *"ដើម្បីមុខការ"*
- ឯកសារនិងកាលប្បវត្តិ។